Los Angeles County
Metropolitan Transportation Authority

One Gateway Plaza
Los Angeles, CA 90012-2952

Metro

ជូនចំពោះមិត្តភ័ក្តជាទីគោរពរាប់អាន

អនាគតដ៏រុងរឿងថែមទៀតសសម្រាប់ខោនធីនៃទីក្រុងឡូសអានជេលេស Los Angeles County ពឹងផ្អែកទៅលើសមត្ថភាពរួមរបស់យើង ដើម្បីធ្វើឱ្យប្រជាពលរដ្ឋអាចធ្វើដំណើរកាន់តែមានប្រសិទ្ធភាពនៅទូទាំងតំបន់។ លទ្ធភាពនៃការធ្វើដំណើរប្រសើរជាងមុនចំពោះការទទួលបានឱកាសកាន់តែច្រើនសម្រាប់មនុស្សទាំងអស់ ដែលរួមមានការងារ ការអប់រំ លំនៅដ្ឋាន និងការថែទាំសុខភាព ដែលជាធាតុសំខាន់ចាំបាច់សម្រាប់គុណភាពជីវិតរស់នៅមានកម្រិតខ្ពស់ជាង។ ដោយសារក្រុមហ៊ុនមេត្រូ Metro អនុវត្តកម្មវិធីពង្រីកការដឹកជញ្ជូនដ៏ធំបំផុតនៅក្នុងប្រទេសនេះ យើងខ្ញុំមានឱកាសដើម្បីធ្វើឱ្យប្រសើរឡើងគុណភាពសេវាកម្មដែលមានស្រាប់របស់យើង នឹងលើកកម្ពស់តាមមធ្យោបាយទាំងអស់នៅក្នុងប្រព័ន្ធរបស់យើង សម្រាប់ការធ្វើដំណើរដែលអាចទុកចិត្តបាន ងាយស្រួល និងមានសុវត្ថិភាពគ្រប់ទីកន្លែងនៅក្នុងខោនធីនេះ។ ផែនការចក្ខុវិស័យក្រុមហ៊ុនមេត្រូឆ្នាំ 2028 (Metro Vision 2028) ស្នើសុំការដោះស្រាយដ៏ទូលំទូលាយមួយ ដើម្បីផ្លាស់ប្តូរការធ្វើដំណើររបស់យើងនាពេលអនាគតតាមរយៈការកំណត់អតិថិជនជាបេះដូងថាតើយើងខ្ញុំរៀបចំគម្រោង និងប្រតិបត្តិការប្រព័ន្ធដឹកជញ្ជូនរបស់យើងតាមរបៀបណា។ ហើយតាមរយៈអតិថិជន ខ្ញុំមានន័យថាអ្នកគ្រប់គ្នាដែលរស់នៅ ធ្វើការ ឬលេងនៅក្នុងខោនធីនៃទីក្រុងឡូសអាន់ជេលេស LA County។

យើងខ្ញុំកំពុងស្ថិតនៅក្នុងដំណាក់កាលសំខាន់មួយនៅក្នុងខោនធី ខោនធីនៃទីក្រុងឡូសអាន់ជេលេស LA County; មិនមានពេលវេលាដែលត្រូវបាត់បង់ឡើយ។ យើងខ្ញុំត្រូវតែចាប់យកឱកាសនេះ ដើម្បីបន្តដំណើរការប្រកបដោយនិរន្តភាពនាពេលអនាគតតាមរយៈការចាត់វិធានការឥឡូវនេះ ដើម្បីគ្រប់គ្រងសមត្ថភាព និងបង្កើនប្រសិទ្ធភាពប្រព័ន្ធដឹកជញ្ជូនរបស់យើង។ ចក្ខុវិស័យក្រុមហ៊ុនមេត្រូឆ្នាំ 2028 (Metro Vision 2028) គឺជាយុទ្ធសាស្ត្រសម្រាប់បង្កើនគុណភាពសេវាកម្មរបស់យើង ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងសម្រាប់មនុស្សគ្រប់គ្នា។

បញ្ហាប្រឈមការដឹកជញ្ជូននៅក្នុងតំបន់នៃរដ្ឋកាលីហ្វ័រនីញ៉ា California ភាគខាងត្បូង តម្រូវឱ្យមានវិធានច្បាស់លាស់។ ចក្ខុវិស័យក្រុមហ៊ុនមេត្រូឆ្នាំ 2028 (Metro Vision 2028) ប្រកាសអំពីគោលបំណងរបស់យើង ដើម្បីទទួលយកដំណោះស្រាយដែលផ្លាស់ប្តូររបៀបថ្មី និងមិនធ្លាប់មានពីមុនមក ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ដំណោះស្រាយតម្រូវឱ្យមានមធ្យោបាយដោះស្រាយរួម និងទូលំទូលាយពីប្រជាពលរដ្ឋទាំងអស់នៅក្នុងតំបន់នេះដែលរួមទាំងលោកអ្នកម្នាក់ៗផងដែរ។ សូមគិតពិចារណាអំពីចក្ខុវិស័យឆ្នាំ 2028 (Vision 2028ជាការអញ្ជើញលោកអ្នករាល់គ្នានៅក្នុងខោនធីឡូសអាន់ជេលេស LA County ដើម្បីចូលរួមជាមួយយើងខ្ញុំ ក្នុងការធ្វើដំណើរឆ្ពោះរកការធ្វើដំណើរកាន់តែប្រសើរឡើងនាពេលអនាគត។

ដោយក្តីគោរពខ្ពង់ខ្ពស់

Phillip A. Washington
ប្រធានភ្នាក់ងារប្រតិបត្តិការ

# សេចក្តីសង្ខេបអំពីផ្នែកប្រតិបត្តិការ

## ផែនការតាមចក្ខុវិស័យក្រុមហ៊ុនមេត្រូឆ្នាំ 2028 (Metro Vision 2028) ("ផែនការ")

គឺជាផែនការយុទ្ធសាស្ត្រទូលំទូលាយរបស់ទីភ្នាក់ងារ ដែលបង្កើតមូលដ្ឋានសម្រាប់ការផ្លាស់ប្តូរការធ្វើចរាចរណ៍នៅខោនធីឡូសអាន់ជេលេស ស Los Angeles County (LA County)ក្នុងរយៈពេល 10 ឆ្នាំខាងមុខ។ ដោយផ្អែកលើការផ្សព្វផ្សាយអស់រយៈពេលជាងមួយឆ្នាំ ផែនការកំណត់បេសកកម្ម ចក្ខុវិស័យ លទ្ធផលអនុវត្ត និងគោលដៅសម្រាប់ Metro និងដាក់បញ្ចូលគំនិតផ្តួចផ្តើម និងលទ្ធផលអនុវត្តជាក់លាក់ចំពោះ Metro និងដៃគូរបស់ខ្លួន នឹងខិតខំប្រឹងប្រែងក្នុងការបន្តដំណើរការមធ្យោបាយដឹកជញ្ជូនកាន់តែល្អប្រសើរឡើងនាពេលអនាគត។

## ការផ្សព្វផ្សាយ

ចក្ខុវិស័យឆ្នាំ 2028 (Vision 2028)គឺជាលទ្ធផលនៃការស្រាវជ្រាវ ការពិភាក្សា និងការផ្សព្វផ្សាយអស់រយៈពេលជាង 18 ខែ។ Metro បានព្យាយាមទទួលបានតម្រូវការឬមតិយោបល់ពីអ្នកពាក់ព័ន្ធជាច្រើន និងអ្នកមានឥទ្ធិពលសំខាន់ៗ ហើយយើងខ្ញុំបានស្ទង់មតិអតិថិជននានា (បានកំណត់អ្នកដែលរស់នៅឬធ្វើការនៅក្នុងខោនធីឡូសអាន់ជេលេស LA County) និងបុគ្គលិករបស់យើង។ Metro បានសិក្សាពីលំដាប់ទស្សនវិស័យនានា និងដោយផ្អែកលើការផ្សព្វផ្សាយនោះ យើងខ្ញុំបានកំណត់និន្នាការសំខាន់ៗដូចខាងក្រោម ដែលរៀបរាប់ពីបញ្ហាប្រឈម និងភាពស្មុគស្មាញនៃការដាក់បញ្ចូលប្រព័ន្ធចរាចរណ៍ដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលជូនប្រជាពលរដ្ឋនៅខោនធីឡូសអាន់ជេលេស LA County៖

- ការរីកចម្រើនឡើងជាបន្តតាមតម្រូវការទាមទារ មានទំនាក់ទំនងនឹងប្រព័ន្ធមធ្យោបាយដឹកជញ្ជូនដែលមានការអនុវត្តច្រើនជាងទីកន្លែងដែលអាចមានរួចមកហើយ
- បញ្ហាប្រឈមក្នុងការបំពេញតាមតម្រូវការ និងការរំពឹងទុកនៃចរាចរណ៍នៅតាមតំបន់ផ្សេងៗគ្នាកំពុងតែមានបញ្ហាស្មុគស្មាញកើនឡើង
- ការច្នៃប្រឌិតផ្នែកបច្ចេកវិទ្យាកំពុងផ្លាស់ប្តូរផ្លូវធ្វើចរាចរណ៍
- កង្វះខាតផ្ទះសម្បែងដែលមានតម្លៃសមរម្យនៅទូទាំងតំបន់ ធ្វើឱ្យមានបញ្ហាប្រឈមនឹងមធ្យោបាយដឹកជញ្ជូនកាន់តែធ្ងន់ធ្ងរ
- ការខកខានធ្វើកំណែទម្រង់គោលនយោបាយ ដែលជួយគាំទ្រដល់ការបើកបររថយន្តតែម្នាក់ឯង នឹងបន្តបន្ថែមការកកស្ទះ និងកាត់បន្ថយការធ្វើចរាចរណ៍

Metro

## បេសកកម្ម និងចក្ខុវិស័យ

បេសកកម្មរបស់ Metro គឺដើម្បីផ្តល់ជូនប្រព័ន្ធដឹកជញ្ជូនលំដាប់ពិភពលោក ដែលធ្វើឱ្យប្រសើរឡើងគុណភាពនៃជីវិតសម្រាប់អ្នកដែលរស់នៅធ្វើការ និងលេងនៅខោនធីឡូសអាន់ដ្យេលេស LA County ។ ចក្ខុវិស័យរបស់ Metro មានសមាសភាពបីយ៉ាង៖

- បង្កើនភាពចម្រុងចម្រើនសម្រាប់អ្នកទាំងអស់គ្នា តាមរយៈការលុបបំបាត់ឧបសគ្គនៃការធ្វើចរាចរណ៍។
- ការធ្វើចរាចរណ៍មានល្បឿនលឿននិងងាយស្រួលធ្វើដំណើរនៅទូទាំងខោនធីឡូសអាន់ដ្យេលេស LA County; និង
- ការសម្របសម្រួលដល់ការធ្វើដំណើរកាន់តែច្រើន តាមរយៈជម្រើសនៃការធ្វើចរាចរណ៍ដែលមានគុណភាពខ្ពស់

ផែនការនេះទទួលស្គាល់ថាខោនធីឡូសអាន់ដ្យេលេស LA County មានប្រព័ន្ធអេកូដឹកជញ្ជូនដែលស្មុគស្មាញ ដែលគ្រប់គ្រងដោយទីភ្នាក់ងារផ្នែកការងារជួសជុលផ្លូវប្រចាំមូលដ្ឋានតំបន់ សហព័ន្ធ និងរដ្ឋ។ តំបន់របស់យើងប្រឈមនឹងបញ្ហាចរាចរណ៍ជាច្រើន ដែលជារឿយៗហាក់ដូចជាមិនអាចដោះស្រាយបាន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំត្រូវតែធ្វើការរួមគ្នាជាមួយដៃគូប្រចាំតំបន់របស់យើង ដែលអាចជួយឱ្យបណ្តាញនេះសម្របសម្រួលដល់ការធ្វើចរាចរណ៍ប្រកបដោយប្រសិទ្ធភាពថែមទៀតសម្រាប់ប្រជាពលរដ្ឋ និងទំនិញ។ ចក្ខុវិស័យឆ្នាំ 2028 (Vision 2028) កំណត់អតិថិជនថាជាបេះដូងនៃការធ្វើដំណើរ ដោយមានការកំណត់អាទិភាពនៃការធ្វើចរាចរណ៍សម្រាប់ប្រជាពលរដ្ឋដែលប្រើប្រាស់យានយន្ត និងការប្រើប្រាស់បណ្តាញដែលមានស្រាប់របស់យើងកាន់តែមានប្រសិទ្ធភាពថែមទៀត។

## លទ្ធផលនៃការអនុវត្ត

ប្រព័ន្ធដឹកជញ្ជូនបច្ចុប្បន្នរបស់យើង មានការកកស្ទះខ្លាំង ដោយសារតែទីធ្លាផ្លូវថ្នល់ដែលប្រើប្រាស់ មិនមានប្រសិទ្ធភាព។ ទីធ្លាផ្លូវថ្នល់មានកំណត់ ដែលផ្តល់ជូនភាគច្រើនសម្រាប់អ្នកបើកបររថយន្តម្នាក់ឯង ដែលជាញឹកញាប់ច្រើនតែជាប់កកស្ទះចរាចរណ៍ នៅខណៈពេលដែលសមាជិកសហគមន៍របស់យើងជួបការលំបាកភាគច្រើន ត្រូវបានកំណត់លក្ខខណ្ឌជម្រើសដឹកជញ្ជូន ដែលជារឿយៗមិនបំពេញតាមតម្រូវការទាមទារនៃការធ្វើចរាចរណ៍ឡើយ។ យើងខ្ញុំត្រូវការប្រើប្រាស់ទីកន្លែងសាធារណៈកាន់តែមានប្រសិទ្ធភាពថែមទៀត នៅខណៈពេលផ្តល់ជូនជម្រើសដែលមានគុណភាពខ្ពស់សម្រាប់អ្នកដែលនៅជុំវិញ។ ដោយមានសមត្ថភាពផ្លូវថ្នល់ដែលមានស្រាប់ដែលគ្រប់គ្រងបានល្អប្រសើរនោះ អ្នកប្រើប្រាស់ទាំងអស់នៅខោនធីឡូសអាន់ដ្យេលេស LA County អាចមានការធ្វើចរាចរណ៍កាន់តែច្រើន។

លទ្ធផលនៃចក្ខុវិស័យរបស់ Metro មានបំណងបង្កើនទ្វេដងចំពោះភាគរយប្រើប្រាស់តាមគំរូមធ្យោបាយដឹកជញ្ជូនក្រៅពីការបើកបររថយន្តតែម្នាក់ឯង ដែលរួមមានការធ្វើដំណើរឆ្លងកាត់ ការដើរ ការជិះកង់ ការធ្វើដំណើររួមគ្នា និងការធ្វើដំណើរដោយជិះរយន្តតែមួយ ដោយសម្រេចបានចំណុចដូចខាងក្រោម៖៖

- ធានាថាអ្នករស់នៅក្នុងខោនធី County ទាំងអស់ អាចប្រើប្រាស់តាមជម្រើសនៃការធ្វើចរាចរណ៍ដែលមានគុណភាពខ្ពស់ក្នុងការដើរ ឬ.... ពីផ្ទះរយៈពេល 10 នាទី
- កាត់បន្ថយពេលវេលារង់ចាំកម្រិតអតិបរមាសម្រាប់ការធ្វើដំណើរណាមួយដែលមានរយៈរហូតដល់ 15 នាទី នៅអំឡុងពេលថ្ងៃ
- ធ្វើឱ្យប្រសើរឡើងល្បឿនធ្វើដំណើរជាមធ្យមតាមបណ្ដាញរថយន្តក្រុងនៅខោនធី County ត្រឹម 30%
- ផ្តល់ជូនជម្រើសដែលអាចទុកចិត្ត និងងាយស្រួលសម្រាប់អ្នកប្រើប្រាស់ដើម្បីចៀសវាងការកកស្ទះចរាចរណ៍

## គោលដៅតាមចក្ខុវិស័យឆ្នាំ **2028 (Vision 2028)**

ដើម្បីដោះស្រាយនិន្នាការទាំងនេះ និងសម្រេចបានលទ្ធផលចក្ខុវិស័យនោះ ចក្ខុវិស័យឆ្នាំ 2028 (Vision 2028) បញ្ជាក់គោលដៅចំនួនប្រាំ ដូចខាងក្រោម៖

1. ផ្តល់ជូនជម្រើសនៃការធ្វើចរាចរណ៍ដែលមានគុណភាពខ្ពស់ ដែលអាចឱ្យប្រជាពលរដ្ឋចំណាយពេលវេលាធ្វើដំណើរតិចជាងមុន។
2. ផ្តល់ជូនបទពិសោធន៍ធ្វើដំណើរដ៏អស្ចារ្យសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនទាំងអស់។
3. ធ្វើឱ្យប្រសើរឡើងសហគមន៍និងការរស់នៅតាមរយៈការធ្វើចរាចរណ៍ និងការទទួលបានឱកាស;
4. ផ្លាស់ប្តូរខោនធីឡូសអាន់ជេលេស LA County តាមរយៈការសហការថ្នាក់តំបន់ និងថ្នាក់ដឹកនាំថ្នាក់ជាតិ; និង
5. ផ្តល់ជូនការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ ដែលទទួលរ៉ាប់រង និងគួរឱ្យទុកចិត្តនៅក្នុងអង្គភាព Metro

សកម្មភាពនៃតារាងម៉ាទ្រីក Action Matrix ដែលមាននៅផ្នែកបញ្ចប់នៃផែនការនេះ សង្ខេបអំពីគោលដៅ គំនិតផ្តួចផ្តើម និងសកម្មភាពនានាដែល Metro នឹងត្រូវអនុវត្ត។ Metro នឹងចេញរបាយការណ៍តាមពេលវេលាទៀងទាត់ដល់សាធារណជនអំពីដំណើរការរីកចម្រើនឆ្ពោះទៅរកគោលដៅ និងគំនិតផ្តួចផ្តើមទាំងនេះ ហើយយើងខ្ញុំនឹងពិនិត្យមើលឡើងវិញនូវផែនការនេះជារៀងរាល់ប្រាំឆ្នាំម្តង ដើម្បីធានាថាយើងខ្ញុំកំពុងតែឆ្ពោះទៅរកចក្ខុវិស័យរបស់យើង។

ការដោះស្រាយបញ្ហាប្រឈមនឹងការដឹកជញ្ជូនរបស់ខោនធីឡូសអាន់ដ្យេលេស LA County តម្រូវឱ្យមានសកម្មភាព ភាពជាអ្នកដឹកនាំច្បាស់លាស់ និងការជួយគាំទ្រយ៉ាងទូលំទូលាយ។ ការលុបបំបាត់បញ្ហាដឹកជញ្ជូន នឹងជួយបំពេញ និងធានាដល់ការសន្យាផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ខោនធីឡូសអាន់ដ្យេលេស LA County ដែលផ្លាស់ប្តូរតំបន់នេះជាទីកន្លែងដែលសប្បាយរីករាយ កាន់តែមានភាពរស់រវើក និងមានសមធម៌ថែមទៀត ដើម្បីរស់នៅ និងធ្វើការ។

## ការដោះស្រាយបញ្ហាប្រឈមនឹងការដឹកជញ្ជូនរបស់ខោនធីឡូសអាន់ដ្យេលេស LA County តម្រូវឱ្យមានសកម្មភាព ភាពជាអ្នកដឹកនាំច្បាស់លាស់ និងការជួយគាំទ្រយ៉ាងទូលំទូលាយ។

19-0193PS ©2018 LACMTA